**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិអតីតយុទ្ធជន**
លេខ ៥៧៤ ប.ជ.អ.

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើបច្ចុប្បន្នភាពជូនអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជន ដែលស្ថិតក្រោមការគ្រប់គ្រង និងបើករបបសន្តិសុខសង្គមរបស់ការិយាល័យបេឡាជាតិអតីតយុទ្ធជន នៅតាមបណ្តារាជធានី ខេត្ត ទាំង ២៥

បេឡាជាតិអតីតយុទ្ធជន សូមជម្រាបជូនដំណឹងដល់និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនពិការ ជាអតីតយុទ្ធជន និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យបេឡាជាតិអតីតយុទ្ធជនទាំង ២៥ រាជធានី ខេត្ត ដែលមិនទាន់មកធ្វើបច្ចុប្បន្នភាពចាប់តាំងពីខែកញ្ញា ឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ននេះ ឲ្យបានជ្រាបថា ក្រុមការងារបេឡាជាតិអតីតយុទ្ធជន បានធ្វើបច្ចុប្បន្នភាពជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន នៅតាមបណ្តារាជធានី ខេត្ត បានចំនួន ២១ រួចមកហើយរួមមានៈ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហានុ ត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី ស្ទឹងត្រែង ឧត្តរមានជ័យ ប៉ៃលិន ស្វាយរៀង រតនៈគិរី កោះកុង កំពង់ធំ កំពង់ចាម ពោធិសាត់ បាត់ដំបង តាកែវ កំពត កែប និងខេត្តកំពង់ឆ្នាំង ។ ចំណែកខេត្តដែលនៅសេសសល់ចំនួន ៤ ទៀតរួមមានៈ ខេត្តព្រះវិហារ សៀមរាប និងខេត្តបន្ទាយមានជ័យ ក្រុមការងារនឹងបន្តចុះធ្វើបច្ចុប្បន្នភាពជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន នៅធនាគារអេស៊ីលីដា ភីអិលស៊ី **ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦** ដោយឡែក ខេត្តព្រៃវែង **ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦** ។

អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន ដែលមកធ្វើបច្ចុប្បន្នភាពត្រូវភ្ជាប់មកជាមួយនូវ ៖
- សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម)
- សាលាកបត្រព័ត៌មានដែលខ្លួនបានបំពេញ តាមរយៈការិយាល័យបេឡាជាតិអតីតយុទ្ធជន រាជធានី ខេត្តឬសាខាបេឡាជាតិអតីតយុទ្ធជន ក្រុង ស្រុក នៃរាជធានី ខេត្ត នីមួយៗ
- លិខិតទទួលស្គាល់ឬ សៀវភៅបើកប្រាក់ ឬ ប្រកាសទទួលស្គាល់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

បេឡាជាតិអតីតយុទ្ធជនសង្ឃឹមជឿជាក់ថា បងប្អូនអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារអតីតយុទ្ធជន និងចូលរួមសហការដើម្បីឲ្យការធ្វើបច្ចុប្បន្នភាពអាចប្រព្រឹត្តទៅបានតាមការគ្រោងទុក។ ចំពោះការខកខានក្នុងការធ្វើបច្ចុប្បន្នភាពតាមកាលបរិច្ឆេទកំណត់ខាងលើនេះ គឺមានន័យថាបងប្អូនអតីតយុទ្ធជនបោះបង់ចោលប្រាក់របបសន្តិសុខសង្គមប្រចាំខែរបស់ខ្លួន ហើយបេឡាជាតិអតីតយុទ្ធជន នឹងលុបឈ្មោះចេញពីបញ្ជីបើកប្រាក់ប្រចាំខែ។ ក្នុងករណីបងប្អូនមកបង្ហាញមុខដើម្បីធ្វើបច្ចុប្បន្នភាពឡើងវិញ បេឡាជាតិអតីតយុទ្ធជន នឹងរៀបចំនីតិវិធី និងបែបបទដើម្បីផ្តល់របបសន្តិសុខសង្គមជូនបងប្អូនវិញ ចាប់ពីពេលដែលបើកផ្តល់ប្រាក់របបសន្តិសុខសង្គមតាមប្រព័ន្ធ **ធនាគារកាណាឌីយ៉ា ក.អ** រាជធានីភ្នំពេញ និង **ធនាគារអេស៊ីលីដា ភីអិលស៊ី** តាមបណ្តាខេត្តនីមួយៗ ។



បេឡាជាតិអតីតយុទ្ធជន ស្ថិតនៅបន្ទប់លេខ A2-01 នៃអគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ: (៨៥៥)០២៣ ២១៣ ៥៨០
National Fund for Veterans. Room A2-01 #788 Monivong Blvd., Phnom Penh. Cambodia. Fax/Phone: 023 215 296

<u>បញ្ជាក់</u>៖ ចំពោះអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនដែលមានជំងឺមិនអាចមកធ្វើបច្ចុប្បន្នភាពតាមសេចក្តីជូនដំណឹងខាងលើនេះ បេឡាជាតិអតីតយុទ្ធជន នឹងចាត់ក្រុមការងារបេឡាជាតិអតីតយុទ្ធជនចុះធ្វើបច្ចុប្បន្នភាពជូនដល់លំនៅដ្ឋានជាក់ស្តែង តាមកាលបរិច្ឆេទណាមួយសមរម្យ ។

**កន្លែងទទួល:**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានីភ្នំពេញ
- សាលាខេត្តទាំង ២៤
- មន្ទីរស.អ.យ.រាជធានី-ខេត្ត
- ការិយាល័យប.ជ.អ. រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ
- ធនាគារកាណាឌីយ៉ា ក.អ
- ធនាគារអេស៊ីលីដា ភីអិលស៊ី
- ឯកសារ-កាលប្បវត្តិ